ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃការវាយតម្លៃបច្ច័យនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា និងទទួលផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់

**ក្រុមប្រឹក្សាជាតិគាំពារសង្គម** មានកិត្តិយសសូមជម្រាបជូនសាធារណជន និងសារព័ត៌មានជាតិ-អន្តរជាតិជម្រាបថា៖ ក្នុងស្មារតី “**មិនបោះបង់ពលរដ្ឋណាម្នាក់**” និងដើម្បីធានានូវសន្តិសុខប្រាក់ចំណូល និងកាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច, រាជរដ្ឋាភិបាលបានបង្កើត និងអភិវឌ្ឍប្រព័ន្ធគាំពារសង្គមជាជំហានៗ ដោយផ្តោតលើការកសាងភាពធន់ និងភាពទន់ភ្លន់ស្របនឹងការវិវត្តនៃកត្តាសេដ្ឋកិច្ច និងសង្គម ព្រមទាំងអាចឆ្លើយតបបានទាន់ពេល ក្នុងគ្រាមានគ្រោះអាសន្នកើតឡើងជាយថាហេតុ។

កន្លងមក ក្នុងគ្រាដែលពិភពលោកបានរងគ្រោះដោយការរីករាលដាលនៃជំងឺកូវីដ-១៩ និងការជះឥទ្ធិពលអវិជ្ជមានពីជម្លោះរវាង **រុស្ស៊ី និង អ៊ុយក្រែន** កាលពីដើមឆ្នាំ ២០២២ ដែលបណ្តាលឱ្យមានការកើនឡើងខ្ពស់នៃថ្លៃទំនិញជាសកល ក៏ដូចជាគ្រោះទឹកជំនន់ធ្ងន់ធ្ងរនៅតាមបណ្តាខេត្តមួយចំនួននៅកម្ពុជា, រាជរដ្ឋាភិបាលបានដាក់ចេញនូវអន្តរាគមន៍ជំនួយសង្គមជាបន្ទាន់មួយចំនួន ដើម្បីជួយស្រូបយកសម្ពាធពីការកើនឡើងនៃអតិផរណា និងកាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច របស់ពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។ អន្តរាគមន៍ទាំងនោះរួមមាន (១) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដែលបានដាក់ឱ្យអនុវត្តកាលពីខែមិថុនា ឆ្នាំ២០២០ រហូតដល់បច្ចុប្បន្ន ដោយបានគ្របដណ្តប់ពលរដ្ឋប្រមាណ **៧០ម៉ឺនគ្រួសារ** ឬស្មើនឹង **២,៨ លាននាក់** ជាមួយនឹងការប្រើប្រាស់ថវិកាជាតិសរុបប្រមាណជាង **៤ ៩៧៥ ០២៥ ៣៩៥ ០០០ រៀល** ឬស្មើនឹង **១ ២៤៣,៧៥ លានដុល្លារ**, និង (២) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា និងគ្រោះទឹកជំនន់ ដោយគ្របដណ្តប់គ្រួសារងាយរងហានិភ័យ ចំនួនប្រមាណ **៥០ម៉ឺនគ្រួសារ** ស្មើនឹងប្រមាណ **១,៨ លាននាក់** ដែលត្រូវបានរាជរដ្ឋាភិបាល បានសម្រេចដាក់ឱ្យអនុវត្តកាលពីចុងឆ្នាំ២០២២ និងបានបិទបញ្ចប់កាលពីខែកក្កដា ឆ្នាំ២០២៣ កន្លងទៅនេះ ដោយបានចំណាយថវិកាជាតិសរុបចំនួន **២២២ ៧៥១ ៩២៤ ០០០ រៀល** ឬស្មើនឹងប្រមាណ **៥៥,៧ លានដុល្លារ**។

បន្ទាប់ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា និងគ្រោះទឹកជំនន់បានបិទបញ្ចប់, **ក្រុមប្រឹក្សាជាតិគាំពារសង្គម** និង**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)** បានសិក្សាវាយតម្លៃរួមគ្នា ដោយរកឃើញថាអន្តរាគមន៍ជំនួយសង្គមពិសេសទាំង ២ នេះ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយបច្ច័យអវិជ្ជមានមកលើគ្រួសារងាយរងហានិភ័យ។ ជាក់ស្តែង គ្រួសារគោលដៅ

ទទួលផលប្រមាណជាង **៩៧%** ពេញចិត្ត និងគាំទ្រការអន្តរាគមន៍ជាការឧបត្ថម្ភសាច់ប្រាក់ របស់រាជរដ្ឋាភិបាល ដោយអ្នកទទួលផលយកទៅប្រើប្រាស់ទៅលើមុខចំណាយចាំបាច់ដូចការរំពឹងទុក ជាពិសេសចំណាយលើ **ម្ហូបអាហារ, សេវាសុខាភិបាល និងឱសថ, ការសិក្សារបស់កូន, ថ្លៃសេវាទឹក-ភ្លើង, ជួលផ្ទះ, និងចំណាយចាំបាច់ផ្សេងៗ។**

លទ្ធផលដដែលនេះ បានបង្ហាញថាកម្មវិធីឧបត្ថម្ភសាច់ប្រាក់ទាំង២ បានទប់ស្កាត់ពីការធ្លាក់ចុះខ្លាំងនៃស្ថានភាពជីវភាពរបស់គ្រួសារគោលដៅ ដូចមានបង្ហាញក្នុងសូចនាករសង្គម-សេដ្ឋកិច្ចសំខាន់ៗខាងក្រោម៖

- **បានកាត់បន្ថយការកើនឡើងនៃអត្រាអសន្តិសុខស្បៀងក្នុងគ្រួសារ ចំនួន ១៣%,**
- **បានកាត់បន្ថយការកើនឡើងនៃអត្រាគ្រួសារមិនមានប្រាក់សន្សំ ចំនួន ៧,៥%,**
- **បានកាត់បន្ថយការកើនឡើងនៃអត្រាគ្រួសារយឺតយ៉ាវក្នុងការសងប្រាក់ធនាគារ ចំនួន ២,៤%,**
- **ចំនួនគ្រួសារគោលដៅដែលគ្មានលទ្ធភាពបង់ថ្លៃសេវាទឹក-ភ្លើង និងថ្លៃជួលផ្ទះ ទាបជាងក្រុមគ្រួសារដែលមិនទទួលបានប្រាក់ឧបត្ថម្ភ ចំនួន ១៣%,**
- **ចំនួនគ្រួសារគោលដៅដែលគ្មានលទ្ធភាពបង់ថ្លៃសេវាសុខាភិបាល ទាបជាង ចំនួន ២៧%។**

លទ្ធផលនៃការវាយតម្លៃនេះ ក៏បានបង្ហាញផងដែរថា ស្ទើរតែ **100%** នៃគ្រួសារពលរដ្ឋគោលដៅ ជាពិសេសគ្រួសារងាយរងហានិភ័យដែលទទួលបានសាច់ប្រាក់ឧបត្ថម្ភ មានទស្សនៈវិជ្ជមានមកលើរាជរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន ដែលជាការរួមចំណែកបង្កើន និងពង្រឹងសតិអារម្មណ៍របស់ពលរដ្ឋមកលើរាជរដ្ឋាភិបាលបន្ថែមទៀត។

ជាមួយនឹងលទ្ធផល និងបច្ច័យវិជ្ជមានទាំងនេះ, បញ្ហាប្រឈមមួយចំនួនក៏ត្រូវបានរំលេចផងដែរ ដូចជាការយល់ដឹងនៅមានកម្រិតរបស់គ្រួសារងាយរងហានិភ័យអំពីការកំណត់អត្តសញ្ញាណ និងគ្រួសារគោលដៅមួយចំនួនតូចបានជួបបញ្ហានៅពេលបើកប្រាក់ឧបត្ថម្ភ ដោយសារបញ្ជរធនាគារនៅឆ្ងាយពីលំនៅដ្ឋានរបស់ពួកគាត់។

ក្រោមការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់ និងប្រកបដោយចក្ខុវិស័យច្បាស់លាស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, ក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលមាន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ជាប្រធាន បាន និងកំពុងគិតគូរ ដោះស្រាយជាបន្តបន្ទាប់ និងជាប្រព័ន្ធ ស្របតាមវឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម។

សេចក្តីដូចបានជម្រាបជូនខាងលើនេះ សូមសាធារណជន និងសារព័ត៌មានជាតិ-អន្តរជាតិទាំងអស់ ជ្រាបជាព័ត៌មាន និងចូលរួមផ្សព្វផ្សាយ **លទ្ធផលនៃការវាយតម្លៃបច្ច័យនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា និងគ្រោះទឹកជំនន់** ឱ្យបានទូលំទូលាយ៕

ថ្ងៃអង្គារ ៧កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣
**អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម**